**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមលេខ ២៨ក្រ៦"ច"

ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៣២៥

ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២០

-សំណុំរឿងស៊ើបសួរលេខ ៣៦៨៣

ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៦០៤៨

ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការនៅថ្ងៃចន្ទ ១៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ ថ្ងៃពុធ ១៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ

### ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### <u>ដើម្បីជំនុំជម្រះ</u>

សំណុំរឿងព្រហ្មទណ្ឌលេខ៥៣២៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ

១-ឈ្មោះ [redacted] មាន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តស្វាយរៀង មុខរបរ កម្មករ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួលគ្មានលេខ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ឃ្លាង "រ" ម្ដាយឈ្មោះ [redacted] ស៊ីថា "រ" ប្រពន្ធឈ្មោះ [redacted] រ៉ាវិន គ្មានកូន ទោសពីមុន គ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨៩១៧"ញ"ដឃដ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។

២-ឈ្មោះ [redacted] រ៉ាវិន ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម មុខរបរ កម្មការិនី ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល ភូមិជម្ពូវ័ន សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចំរើន "រ" ម្ដាយឈ្មោះ [redacted] ស៊ុនហៀង "រ" ប្ដីឈ្មោះ [redacted] មាន គ្មានកូន ទោសពីមុន គ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨៩១៦"ញ"ដឃដ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។



Scanned with CamScanner

ត្រូវចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះជួល ភូមិជម្ពូវ័ន២ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទ។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ

-កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង១៥និង០៥នាទី នៅចំណុចបន្ទប់ជួល ផ្លូវបេតុង ភូមិជម្ពូវ័ន២ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀនរបស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ បានចុះបង្ក្រាបករណីគ្រឿងញៀននៅបន្ទប់ជួលរបស់ឈ្មោះ [redacted] មាន និងឈ្មោះ [redacted] រ៉ាវិន បានរកឃើញក្រាមពណ៌សថ្លាចំនួន២១កញ្ចប់ ទម្ងន់៣០,៩៩ ក្រាម, ថ្នាំគ្រាប់ពណ៌ផ្កាឈូកWY ចំនួន៥៣គ្រាប់ ទម្ងន់៥,២៦ក្រាម, ម្សៅផ្កាឈូកចំនួន២កញ្ចប់ ចំនួន០,១០ ក្រាម, ជញ្ជីងអេឡិចត្រូនិចសម្រាប់ថ្លឹងចំនួន១ និងសម្ភារៈសម្រាប់វេចខ្ចប់គ្រឿងញៀនមួយចំនួន ដែលឈ្មោះ [redacted] មាន និងឈ្មោះ [redacted] រ៉ាវិន ទិញពីជនមិនស្គាល់ឈ្មោះ ភេទប្រុស សម្បុរស្រអែម អាយុប្រហែល ៣០ឆ្នាំ ដែលប្រើប្រាស់លេខទូរស័ព្ទ ០៩៦ ៨៦៧ ១៤៣៨ ក្នុងតម្លៃ៥០០,០០០(ហាសិបម៉ឺន)រៀល ហើយយកវ៉ែកលក់បន្ត។ ក្រោយពីសមត្ថកិច្ចចាប់ខ្លួន និងធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] មាន និងឈ្មោះ [redacted] រ៉ាវិន លទ្ធផលបង្ហាញថា វិជ្ជមាន មានសារធាតុញៀន។

-បានឃើញរបាយការណ៍សំយោគលេខ២៧១ក.ប.គ.ញ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៥៥៩០អយធ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៧១៧២"ញ"ដជ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] មាន បានធ្វើការកត់សម្គាល់ថា កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង១៥និង០៥នាទី សមត្ថកិច្ចឆែកឆេររកឃើញក្រាមពណ៌សថ្លា២១កញ្ចប់ និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញាWY ចំនួន៥៣គ្រាប់ និងម្សៅផ្កាឈូកចំនួន២កញ្ចប់ ជញ្ជីងថ្លឹងគ្រឿងញៀនមួយ ទុយោទុកច្រកមួយកំណាត់ ថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួនដែលជារបស់ខ្លួន ឯប្រពន្ធខ្លួនឈ្មោះ [redacted] រ៉ាវិន បានដឹង តែពុំបានចូលរួមជាមួយខ្លួនទេ គ្រឿងញៀនទាំងពីរមុខនេះខ្លួនទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល ៣០ឆ្នាំ សម្បុរស្រអែម កម្ពស់ប្រហែល១ម៉ែត្រ៦៣សង់ទីម៉ែត្រ នៅម្តុំក្តាន់ពីរ ដោយពេលទិញម្តងៗ គឺទាក់ទងគ្នាតាមទូរស័ព្ទគឺ ០៩៦ ៨៦៧ ១៤៣៨ ក្នុងតម្លៃមួយកញ្ចប់៣០ម៉ឺនរៀល និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញា WY ម្តងចំនួន៥០គ្រាប់ ក្នុងតម្លៃ២០ម៉ឺនរៀល ចំណែកក្រាមពណ៌សថ្លាមួយកញ្ចប់នេះ ខ្លួនបានយកបំបែកបាន២៦កញ្ចប់ ហើយលក់ចេញវិញ១កញ្ចប់១០ដុល្លារអាមេរិក លក់អស់៥កញ្ចប់ នៅសល់២១កញ្ចប់។ ថ្នាំគ្រាប់លក់អស់២គ្រាប់ មួយគ្រាប់តម្លៃ៣ដុល្លារអាមេរិក នៅសល់៥៣គ្រាប់ ចំណែកម្សៅពណ៌ផ្កាឈូកពីរកញ្ចប់



Scanned with CamScanner

នេះគេអ្នកលក់គ្រឿងញៀនគេថែមឱ្យ។ ខ្លួនធ្លាប់រកស៊ីគ្រឿងញៀនបីខែហើយ ដោយធ្លាប់ទិញពីបុរសនេះដើម្បីលក់បន្ត ក្នុងមួយថ្ងៃខ្លួនលក់បាន១០កញ្ចប់។ ក្នុងពេលលក់អស់ចំណេញបានប្រាក់១០ម៉ឺនរៀល។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេល៤ខែហើយ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ាវិន បានធ្វើការកត់សម្គាល់ថា កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង១៥និង០៥នាទី សមត្ថកិច្ចឆែកឆេររកឃើញក្រាមពណ៌សថ្លា២១កញ្ចប់ និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញាWY ចំនួន៥៣គ្រាប់ និងម្សៅផ្កាឈូកចំនួន២កញ្ចប់ ជញ្ជីងថ្លឹងគ្រឿងញៀនមួយ ទុយោទុកច្រកមួយកំណាត់ ផង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួនដែលជារបស់ប្ដីឈ្មោះ [redacted] មាន។ គ្រឿងញៀនទាំងពីរមុខនេះ ប្ដីខ្លួនជាអ្នកទៅទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះ ហើយក៏មិនដឹងថា ទិញក្នុងតម្លៃប៉ុន្មានដែរ តែពេលទិញមកឃើញមានក្រាមពីរប្រភេទមានជាក្រាម និងជាគ្រាប់ ហើយប្ដីខ្លួនបានយកមកបំបែកថ្លឹងច្រកចូលផង់នៅបន្ទប់ជួលនៅនឹងមុខខ្លួន ហើយគាត់បានយកទៅលក់នៅក្រៅតែម្នាក់ឯង តែមួយរយៈក្រោយនេះ គាត់ឱ្យគេចេញចូលទិញគ្រឿងញៀនដល់បន្ទប់ជួល ក្នុងមួយថ្ងៃគាត់លក់បានគ្រឿងញៀនប៉ុន្មានកញ្ចប់ខ្លួនពុំដឹងទេ តែខ្លួនដឹងថាគាត់លក់គ្រឿងញៀន៤ខែហើយ។ ខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដែរ គឺចេះប្រើប្រាស់ជាងមួយអាទិត្យហើយ។

-បានពិនិត្យឯកសារភស្តុតាងនានា

**<u>តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា</u>**

ក្រោយពីបានពិនិត្យភស្តុតាងក្នុងសំណុំរឿង តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ៥៥៩០អយច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដដែល។

**<u>មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា</u>**

កូនក្ដីខ្លួនឈ្មោះ [redacted] មាន ទទួលស្គាល់កំហុសពីការជួញដូរគ្រឿងញៀននេះពិតមែន ហេតុនេះស្នើសុំតុលាការបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនផង។ ចំណែកកូនក្ដីឈ្មោះ [redacted] រ៉ាវិន បានឆ្លើយបដិសេធមិនបានប្រព្រឹត្តទេ ឯឈ្មោះ [redacted] មាន ក៏បានបញ្ជាក់ថា ប្រពន្ធពុំមានពាក់ព័ន្ធទេ សុំតុលាការសម្រេចឱ្យរួចខ្លួន។

**<u>ជនជាប់ចោទបានសំណូមពរចុងក្រោយថា</u>**

ឈ្មោះ [redacted] មាន សុំបន្ធូរបន្ថយទោស។

ឈ្មោះ [redacted] រ៉ាវិន សុំលើកលែងចោទប្រកាន់។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានលទ្ធផលកោសល្យវិច័យគ្រឿងញៀន

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## <u>សាលាដំបូងរាជធានីភ្នំពេញ</u>

## <u>យល់ឃើញថា</u>

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted]មាន ថា កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០៥នាទី សមត្ថកិច្ចឆែកឆេររកឃើញក្រាមពណ៌សថ្លា២១កញ្ចប់ និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញាWY ចំនួន៥៣គ្រាប់ និងម្សៅផ្កាឈូកចំនួន២កញ្ចប់ ជញ្ជីងថ្លឹងគ្រឿងញៀនមួយ ទុយោទុកច្រកមួយកំណាត់ ថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួនដែលជារបស់ខ្លួន។ គ្រឿងញៀនទាំងពីរមុខនេះខ្លួនទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល៣០ឆ្នាំ សម្បុរស្រអែម កម្ពស់ប្រហែល១ម៉ែត្រ៦៣សង់ទីម៉ែត្រ នៅម្ដុំក្ដាន់ពីរ ដោយពេលទិញម្ដងៗ គឺទាក់ទងគ្នាតាមទូរស័ព្ទគឺ ០៩៦ ៨៦៧ ១៤៣៨ ក្នុងតម្លៃមួយកញ្ចប់៣០ម៉ឺនរៀល និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញាWY ម្ដងចំនួន៥០គ្រាប់ ក្នុងតម្លៃ២០ម៉ឺនរៀល ចំណែកក្រាមពណ៌សថ្លាមួយកញ្ចប់នេះ ខ្លួនបានយកបំបែកបាន២៦កញ្ចប់ ហើយលក់ចេញវិញ១កញ្ចប់១០ដុល្លារអាមេរិក លក់អស់៥កញ្ចប់ នៅសល់២១កញ្ចប់។ ថ្នាំគ្រាប់លក់អស់២គ្រាប់ មួយគ្រាប់តម្លៃ៣ដុល្លារអាមេរិក នៅសល់៥៣គ្រាប់ ចំណែកម្សៅពណ៌ផ្កាឈូកពីរកញ្ចប់នេះគេអ្នកលក់គ្រឿងញៀនគេថែមឱ្យ។ ខ្លួនធ្លាប់រកស៊ីគ្រឿងញៀនបីខែហើយ ដោយធ្លាប់ទិញពីបុរសនេះដើម្បីលក់បន្ត ក្នុងមួយថ្ងៃខ្លួននិងប្រពន្ធឈ្មោះ [redacted] រ៉ាវិន លក់បាន១០កញ្ចប់។ ក្នុងពេលលក់អស់ចំណេញបានប្រាក់១០ម៉ឺនរៀល។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេល៤ខែហើយ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted]រ៉ាវិន ថា កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០៥នាទី សមត្ថកិច្ចឆែកឆេររកឃើញក្រាមពណ៌សថ្លា២១កញ្ចប់ និងថ្នាំគ្រាប់ពណ៌ផ្កាឈូកសញ្ញាWY ចំនួន៥៣គ្រាប់ និងម្សៅផ្កាឈូកចំនួន២កញ្ចប់ ជញ្ជីងថ្លឹងគ្រឿងញៀនមួយ ទុយោទុកច្រកមួយកំណាត់ ថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួនដែលជារបស់ប្ដីឈ្មោះ [redacted]មាន។ គ្រឿងញៀនទាំងពីរមុខនេះ ប្ដីខ្លួនជាអ្នកទៅទិញពីបុរសម្នាក់មិនស្គាល់ឈ្មោះ ហើយក៏មិនដឹងថា ទិញក្នុងតម្លៃប៉ុន្មានដែរ តែពេលទិញមកឃើញមានក្រាមពីរប្រភេទមានជាក្រាម និងជាគ្រាប់ ហើយប្ដីខ្លួនបានយកមកបំបែកថ្លឹងច្រកចូលថង់នៅបន្ទប់ជួលនៅនឹងមុខខ្លួន ហើយគាត់បានយកទៅលក់នៅក្រៅតែម្នាក់ឯង តែមួយរយៈក្រោយនេះ គាត់ឱ្យគេចេញចូលទិញគ្រឿងញៀនដល់បន្ទប់ជួល ក្នុងមួយថ្ងៃគាត់លក់បានគ្រឿងញៀនប៉ុន្មានកញ្ចប់ខ្លួនពុំដឹងទេ តែខ្លួនដឹងថាគាត់លក់គ្រឿងញៀន៤ខែហើយ។ ខ្លួនក៏ចេះប្រើប្រាស់គ្រឿងញៀនដែរ គឺចេះប្រើប្រាស់ជាងមួយអាទិត្យហើយ។

-តាមចម្លើយជនជាប់ចោទទាំងពីរគឺឈ្មោះ [redacted] មាន បានឆ្លើយសារភាព តែដោះបន្ទុកប្រពន្ធខ្លួនឈ្មោះ [redacted] រ៉ាវិន ថា ពុំមានពាក់ព័ន្ធ ឯចម្លើយជនជាប់ចោទឈ្មោះ [redacted] រ៉ាវិន ក៏បានបញ្ជាក់ថា អំពើប្រព្រឹត្តធ្វើឡើងតែប្ដីខ្លួនទេពុំពាក់ព័ន្ធនឹងខ្លួនទេ ចម្លើយរបស់ជនជាប់ចោទទាំងពីរនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងនៅចៅក្រមស៊ើបសួរសុទ្ធតែបានទទួលស្គាល់ថា ថ្នាំញៀនខាងលើ ពួកខ្លួនទាំងពីរនាក់ប្ដីប្រពន្ធសហការគ្នាក្នុងការទិញលក់ តែសកម្មភាពមួយចំនួនធំប្ដីឈ្មោះ [redacted]មាន ជាអ្នកប្រព្រឹត្ត។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរ នៅគ្រប់ដំណាក់កាល លើកលែងតែពេលសវនាការសុទ្ធតែមានភាពស្របគ្នានិងស៊ីសង្វាក់ទៅនឹងការចាប់យកវត្ថុតាងមាន ថ្នាំក្រាមពណ៌សថ្លា ថ្នាំគ្រាប់ និងជញ្ជីងសម្រាប់ថ្លឹងថែមទៀត ដូចនេះចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរល្មមជឿបាន។



Scanned with CamScanner

-អំពើរបស់ជនជាប់ចោទដែលបានទិញថ្នាំញៀនយកមករំលែកជាកញ្ចប់តូចៗ ដើម្បីលក់ឱ្យម៉ូយជាបន្ត នោះគឺជាអំពើទិញដើម្បីលក់ដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើបែបនេះច្បាប់កំណត់ថាជាបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទទាំងពីរទទួលស្គាល់ពីការប្រើប្រាស់ថ្នាំញៀន ស្របតាមលទ្ធផលនៃការធ្វើតេស្តស្វែងរកសារធាតុញៀន ឃើញមានលទ្ធផល វិជ្ជមាន ដូចនេះចម្លើយសារភាពនេះល្មមជឿបាន។

-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ២៨៤៦៨/២០ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ បញ្ជាក់ពីលទ្ធផល វិជ្ជមាន ដែលមានបរិមាណមេតំហ្វេតាមីន ចំនួន៧៩,៩២% និង៦,០១% និង ៦,៩៤% ដូចនេះបញ្ជាក់ថា ថ្នាំញៀន ដែលជនជាប់ចោទទិញដើម្បីលក់នោះ គឺជាថ្នាំញៀន ពិតប្រាកដមែន។

-តាមការពិនិត្យលើចំនួនក្រាមពណ៌សថ្លាទម្ងន់ ៣០,៩៩ក្រាម មានសារធាតុ មេតំហ្វេតាមីន ចំនួន ៧៩,៩២% ក្រាមពណ៌សថ្លាទម្ងន់០,១០ក្រាម មានសារធាតុមេតំហ្វេតាមីន ចំនួន៦,០១% និងថ្នាំគ្រាប់ចំនួន ៥៣គ្រាប់ ស្មើនឹង៥,២៦ក្រាម មានភាគរយមេតំហ្វេតាមីនចំនួន៦,៩៤% សរុបសារធាតុញៀនមេតំហ្វេតាមីន ចំនួន២៥,១៣ក្រាម ដូចនេះអំពើរបស់ជនជាប់ចោទរូបនេះឆ្លើយតបតាមមាត្រា៤០ កថាខណ្ឌទី៣ និងទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] មាន ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] រ៉ាវិន ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ គឺជានីតិជន ដែលមានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ ឃើញថា រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់ ដូចនេះជនជាប់ចោទត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់នូវអំពើរបស់ខ្លួន។

-មានភស្តុតាងធ្ងន់ល្មមលើឈ្មោះ [redacted] មាន និងឈ្មោះ [redacted] រ៉ាវិន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះជួល ភូមិដម្លូវទី២ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៣ និងទី៥ ចំណុចទី៦ មាត្រា៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមរយៈគ្រឿងញៀនខាងលើ ឃើញថា អំពើរបស់ជនជាប់ចោទឈ្មោ[redacted] មាន និងឈ្មោះ [redacted] រ៉ាវិន ពិតជាបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម និងសុខភាពមនុស្ស ដែលតុលាការគប្បីផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] មាន និងឈ្មោះ [redacted] រ៉ាវិន តឹងរឹងតាមច្បាប់។

-តាមការពិនិត្យលើអំពើរបស់ជនជាប់ចោទទាំងពីរ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] មាន បានធ្វើសកម្មភាពយ៉ាងសកម្ម ដោយបានទៅទិញថ្នាំញៀនរំលែកថ្នាំញៀន និងលក់ដោយខ្លួនឯង ដូចនេះគប្បីតុលាការផ្តន្ទាទោសលើជនជាប់ចោទរូបនេះធ្ងន់ជាងឈ្មោះ [redacted] រ៉ាវិន។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ាវិន ភេទស្រី និងពុំបានធ្វើសកម្មភាពសកម្មទេ គប្បីតុលាការអនុវត្តដោយអនុវត្តទោសព្យួរមួយផ្នែក តាមមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

-ដើម្បីអាចឱ្យជនជាប់ចោទរូបនេះកែប្រែខ្លួនចូលក្នុងសង្គមបានល្អ ចៀសវាងការប្រព្រឹត្តបទល្មើសជាថ្មី គប្បីតុលាការសម្រេចអំពីការព្យួរទោសសាកល្បងសម្រាប់ជនជាប់ចោទ តាមមាត្រា១១៧ និងមាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌ និងតម្រូវឱ្យទណ្ឌិតគោរពតាមវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកមួយចំនួន តាមមាត្រា១១៩ និងមាត្រា១២០ នៃក្រមព្រហ្មទណ្ឌ។

-វត្ថុចាប់យកមាន៖ ថ្នាំក្រាមពណ៌សថ្លាទម្ងន់២៩,៩៩ក្រាម និងថ្នាំក្រាមទម្ងន់៥,០៦ក្រាម សល់ពីការដកសំណាក, ជញ្ជីងសម្រាប់ថ្លឹង១ ទុយោចូក១ថង់ សម្រាប់ច្រកគ្រឿងញៀនមួយចំនួន ជាវត្ថុមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ហេតុនេះត្រូវរឹបអូស។

<u>**ហេតុដូច្នេះសម្រេច**</u>

១-ប្រកាសពិរុទ្ធភាពលើ

ក-ឈ្មោះ [redacted]មាន

ខ-ឈ្មោះ [redacted] រ៉ាវិន

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះជួល ភូមិជម្ពូវ័ន២ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៣ និងទី៥ មាត្រា៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] មាន ដាក់ពន្ធនាគារកំណត់រយៈពេល**០៥(ប្រាំ)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន១០.០០០.០០០(ដប់លាន)រៀល។

ខ-ឈ្មោះ [redacted] រ៉ាវិន ដាក់ពន្ធនាគារ**០៥(ប្រាំ)ឆ្នាំ** តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារកំណត់រយៈពេល**០៣(បី)ឆ្នាំ** ឯទោសសល់ពីនេះត្រូវព្យួរសាកល្បង៣ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល។

៣-ក្នុងរយៈពេលសាកល្បងរយៈពេល៣ឆ្នាំ ទណ្ឌិតត្រូវគោរពតាមវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកមួយចំនួនដូចខាងក្រោម៖

៣-១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចឱ្យ។

៣-២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

៣-៣-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

៣-៤-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

៣-៥-ទណ្ឌិតត្រូវទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬព្យាបាល។

៣-៦-ទណ្ឌិតត្រូវបញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

៣-៧-ទណ្ឌិតមិនត្រូវសេពគប់បនល្បែង។



Scanned with CamScanner

៣-៨-ទណ្ឌិតមិនត្រូវសេពគប់គៀមភេសជ្ជៈស្រវឹង។

៤-វត្ថុចាប់យកមាន៖

ក-ថ្នាំក្រាមពណ៌សថ្លាទម្ងន់ ២៩,៩៩ក្រាម និងថ្នាំក្រាមទម្ងន់ ៥,០៦ក្រាម (សល់ពីការដកសំណាក) ជញ្ជីងសម្រាប់ថ្លឹង១, ទុយោចូក១ថង់ សម្រាប់ច្រកគ្រឿងញៀនមួយចំនួន ត្រូវរឹបអូស។

ខ-ប្រាក់រៀលចំនួន៣ម៉ឺនរៀល, ទូរស័ព្ទដៃម៉ាក Iphone 6 plus មួយគ្រឿង និងម៉ូតូម៉ាកនិចពណ៌ខៀវពាក់ស្លាកលេខ 1DF-2237 ត្រូវប្រគល់ឱ្យឈ្មោះ [redacted]មាន និងឈ្មោះ [redacted] រ៉ាវិន ជាម្ចាស់ដើមវិញ។

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងពីរ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។"

រាជធានីភ្នំពេញ.ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner